៩២៥/

103/17

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

-សំណុំរឿងព្រហ្មទណ្ឌលេខៈ ១០៣៦
ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦
-ជំនុំជម្រះលេខ ៖ ២៩៣៦
ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦
-សាលក្រមលេខៈ ៤៨៤ (៣)-ក្រ៨-
ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៧

## គាលនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៧ ដោយមានសមាសភាពដូចតទៅ :

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជំម្រះសាលាដំបូងរាជធានីភ្នំពេញ

លោក [redacted] ចៅក្រមប្រឹក្សាសាលាដំបូងរាជធានីភ្នំពេញ

លោក [redacted] ចៅក្រមប្រឹក្សាសាលាដំបូងរាជធានីភ្នំពេញ

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

កញ្ញា [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

### ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ ១០៣៦ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦។

### ជនជាប់ចោទ

៣- ១-ឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិព្រែកព្នៅ ស្រុកពញាឮ ខេត្តកណ្តាល ទីលំនៅមុនពេលឃាត់ខ្លួនផ្ទះគ្មានលេខ ផ្លូវ [redacted] ង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] មានកូន០១នាក់ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ទោសពីមុន គ្មាន ជានីតិជន។

-មេធាវី [redacted] ឡាយយី ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៣៩៨ "ច".ដ.ឃ.ជ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦។

២-ឈ្មោះ [redacted] លាង ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិវៀតណាម ទីកន្លែងកំណើតនៅ ប្រទេសវៀតណាម ទីលំនៅបច្ចុប្បន្នជាប់ឃុំនៅមណ្ឌលអប់រំកែប្រែទី១(ព្រៃស) ប្រពន្ធឈ្មោះ [redacted] ធីហ្វាងអៀន "រ" មានកូន ២នាក់ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" បច្ចុប្បន្នជាទណ្ឌិតដែលជាប់ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១(ព្រៃស)រយៈពេល៣០ឆ្នាំ ពីបទជួញ ដូរដោយខុសច្បាប់នូវសារធាតុញៀន ជានីតិជន។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៤០៣ "ច".ដ.ឃ.ជ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦។

-លោកមេធាវី [redacted] មុន្នីជាតិ និងមេធាវី [redacted] បញ្ញា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ



Scanned with CamScanner

-លោ[redacted] សេង ជាអ្នកបកប្រែភាសា។

- ៣-ឈ្មោះ [redacted] សៅ ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិគោករកា ឃុំគោករកា ស្រុកជង្កោ ខេត្តកណ្ដាល បច្ចុប្បន្នជាប់ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១(ព្រៃស) ប្រពន្ធឈ្មោះ [redacted] "រ" មានកូន ៤នាក់ ឪពុកឈ្មោះ [redacted] "រ" ម្ដាយឈ្មោះ [redacted] "ស" ជានីតិជន។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៣៩៩ "ច".ដ.ឃ.ជ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦។

-លោកស្រីមេធាវី [redacted] សុខា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

- ៤-ឈ្មោះ [redacted] វង្ហា ហៅ សឹង ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅកម្ពុជាក្រោម ទីលំនៅបច្ចុប្បន្នជាប់ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១(ព្រៃស) ប្រពន្ធឈ្មោះ [redacted] "រ" លែងលះ មានកូន២នាក់ ឪពុកឈ្មោ[redacted] "ស" ម្ដាយឈ្មោះ [redacted] "រ" បច្ចុប្បន្នជាទណ្ឌិតជាប់ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ (ព្រៃស) ជានីតិជន។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៤០០ "ច".ដ.ឃ.ជ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦។

-លោកស្រីមេធា[redacted]សុខា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

- ៥-ឈ្មោះ [redacted] I SAMUEL ភេទប្រុស អាយុ៣៦ឆ្នាំជនជាតិNIGERIAN កើតនៅប្រទេស NIGERIA ទីលំនៅបច្ចុប្បន្ននៅមណ្ឌលអប់រំកែប្រែទី១(ព្រៃស) ប្រពន្ធឈ្មោះ TUI មានកូន០១នាក់ ឪពុកឈ្មោះ AMAECHI "ស" ម្ដាយឈ្មោះ PEACE "ស" បច្ចុប្បន្នកំពុងជាប់ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១(ព្រៃស) រយៈពេល ១ឆ្នាំកន្លះ ពីបទ ជួញដូរដោយខុស ច្បាប់ នូវសារធាតុញៀន ជានីតិជន។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៤០២ "ច".ដ.ឃ.ជ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦។

-មេធាវីលោក[redacted]ទីលីន និងមេធាវី[redacted] នី ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

-លោក ញ៉ែម សម្បត្តិ ជាអ្នកបកប្រែភាសា។

- ៦-ឈ្មោ[redacted] BENTO ភេទប្រុស អាយុ៤១ឆ្នាំ ជនជាតិ BISSAU កើតនៅ ប្រទេស GUINEA ទីលំនៅបច្ចុប្បន្ននៅមណ្ឌលអប់រំកែប្រទី១(ព្រៃស) នៅលីវ ឪពុកឈោះ ALEX BENTO "ស" ម្ដាយឈ្មោះ CHIRSTINA BENTO "ស" បច្ចុប្បន្នជាទណ្ឌិតនៅមណ្ឌលអប់រំកែប្រែទី១ (ព្រៃស) ត្រូវបានតុលាការផ្តន្ទាទោសរយៈពេល ២៧ឆ្នាំ ពីបទ ជួញដូរដោយខុស ច្បាប់នូវសារធាតុញៀន ជានីតិជន។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៤០១ "ច".ដ.ឃ.ជ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦។

-មេធាវី[redacted]វណ្ណារ៉េត និងមេធា[redacted] សេង្ហា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-លោក[redacted]សម្បត្តិ ជាអ្នកបកប្រែភាសា។

៧-ឈ្មោះ [redacted]ថាវី ហៅ [redacted] ក៉ាវី ភេទប្រុស កើតឆ្នាំ១៩៨៣ ជាតិខ្មែរ មុខរបរ នៅផ្ទះ កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០១០៦២០៥៣៨ ទីកន្លែងកំណើតនៅភូមិត្រែង ឃុំ ត្រែង ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង ទីលំនៅបច្ចុប្បន្ន[redacted]ត្រពាំងឈូក

សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្តាយ ឈ្មោះ [redacted]ន ទោសពីមុន ធ្លាប់ជាប់ពន្ធនាគារ ម១ ពីបទ ជួញដូរគ្រឿងញៀន។ (ក្រៅឃុំ)

-លោក [redacted] គ្រុយ និងលោក [redacted] ឡង់ឌី ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

ជាប់ចោទពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចចំណតរថយន្តក្រុងក្រុមហ៊ុនអង្គអ៊ិចប្រេស ផ្លូវជាតិលេខ៥ ក្រុម១៤ ភូមិផ្សារតូច សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ និងបន្ទប់ជួលលេខ៧៧ ភូមិ៤ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ថ្ងៃទី២៩ ខែកុម្ភៈ និងថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-បានឃើញ របាយការណ៍សុបលេខ ០៥៣/១៦ ក.ប.គ.ញ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ របស់ការិយាល័យបទល្មើសគ្រឿងញៀន។

-បានឃើញ ដីកាសម្រេចលេខ ៤៨៥ ព្រទ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ២០០៧ អ.យ.ធ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ២៦២៦ "ច".ដ.ជ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាបង្គាប់ឲ្យនាំជនជាប់ចោទមកសាលាដំបូងរាជធានីភ្នំពេញលេខ ០៤ (៣)ព្រទ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧ របស់ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាបង្គាប់ឲ្យនាំជនជាប់ចោទមកសាលាដំបូងរាជធានីភ្នំពេញលេខ ០៥ (៣)ព្រទ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧ របស់ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៦ វេលាម៉ោង ១៣និង៣០នាទី មន្ត្រីនគរបាលការិយាល័យអន្តរាគមន៍ នៃមន្ទីរប្រឆាំងគ្រឿងញៀនបានឃាត់ខ្លួនជនជាប់ចោទម្នាក់ឈ្មោះ [redacted] ធីវ៉ា ហៅ ត្រា ភេទប្រុស ឆែកឆេរលើខ្លួនឃើញមានក្រាមពណ៌សថ្លាសង្ស័យថាជាសារធាតុញៀនចំនួន២កញ្ចប់ ហើយបានបន្តទៅឆែកឆេរបន្ទប់លេខ៧៧ ភូមិ៤ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ រកឃើញក្រាមពណ៌សថ្លាចំនួន១៩កញ្ចប់ ថ្នាំគ្រាប់ពណ៌ផ្កាឈូក៨កញ្ចប់ និងជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនមួយគ្រឿង។ ក្រោយពីស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ធីវ៉ា ហៅ ត្រា សមត្ថកិច្ចបានបន្តទៅនាំខ្លួនជនជាប់ចោទម្នាក់ និងទណ្ឌិតពីរនាក់ ពីពន្ធនាគារព្រៃស មកសាកសួរយកចម្លើយមានឈ្មោះ [redacted] វង្សា ហៅ សឹង ភេទប្រុស អាយុ ៣៩ឆ្នាំ ,ឈ្មោះ [redacted] សៅ ភេទប្រុស អាយុ ៤៥ឆ្នាំ និងឈ្មោះ [redacted] លាង ភេទប្រុស អាយុ ៣៧ឆ្នាំ។ លុះនៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ ឈ្មោះ [redacted] ធូវ៉ា ហៅ ត្រា ,ឈ្មោះ [redacted] វង្សា ហៅ សឹង និងឈ្មោះ [redacted] សៅ

បានសហការជាមួយសមត្ថកិច្ចដោយឲ្យជនជាប់ចោទឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា នាំសមត្ថកិច្ចទៅយកគ្រឿងញៀនប្រភេទ WY ចំនួន ១៧សុង (ប្រហែល ១០ម៉ឺនគ្រាប់) ដែលពួកគេបានទទួលបញ្ជាពីមេជួញដូរគ្រឿងញៀនក្នុងពន្ធនាគារ ទុកប្រគល់ឲ្យម៉ូយទិញគ្រឿងញៀនយកទៅលក់បន្ត។ តាមចម្លើយសារភាពរបស់ឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា, ឈ្មោះ [redacted]ដ្ឋា ហៅ សឹង ឈ្មោះ [redacted] សៅ គឺទទួលបញ្ជាពីក្នុងពន្ធនាគារ ដោយមានឈ្មោះ [redacted] BENTO ហៅ បាឡា គេទប្រុស, ឈ្មោះ [redacted] SAMUEL ហៅ បាបា គេទប្រុស ជនជាតិស្បែកខ្មៅ និងឈ្មោះ [redacted] លាង ជាមេក្លោងគ្រឿងញៀនបានធ្វើការបញ្ជាឲ្យឈ្មោះ [redacted] ជីក៉ ដែលនៅខាងក្រៅឲ្យធ្វើសកម្មភាពជួញដូរគ្រឿងញៀន និងតាមចម្លើយសារភាពរបស់ឈ្មោះ [redacted] រដ្ឋា ហៅ សឹង បានបញ្ជាក់ថា កន្លងមកឈ្មោះ វី មេជួញដូរគ្រឿងញៀននៅម្ដុំពេទ្យលោកសង្ឃបានទទួលទិញគ្រឿងញៀនពីឈ្មោះ លាង យកទៅលក់បន្ត ហើយឈ្មោះ លាង បានប្រាប់ឲ្យឈ្មោះ [redacted]ដ្ឋា ហៅ សឹង បញ្ជាមកឈ្មោះ [redacted]ធូរ៉ា ហៅ ត្រា ទំនាក់ទំនងឈ្មោះ វី ឡើងវិញ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា បានឆ្លើយថា៖ សមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦ នៅគល់ស្ពានជ្រោយចង្វារ។ ខ្លួនយកថ្នាំញៀនទៅឲ្យគេតាមការបញ្ជារបស់ ឈ្មោះ [redacted] រដ្ឋា ហៅ សឹង ដែលទូរស័ព្ទមកខ្លួន ហើយឈ្មោះ [redacted] រដ្ឋា ហៅ សឹង ប្រាប់ឲ្យខ្លួនធ្វើការងារនេះតាមរយៈឈ្មោះ [redacted] លាង ដោយឲ្យខ្លួនដឹកថ្នាំញៀនទៅឲ្យគេ គឺទៅយកពីជនជាតិស្បែកខ្មៅ យកម្ដង០១គីឡូក្រាម ឬ ០២គីឡូក្រាម។ ខ្លួនយកថ្នាំញៀននេះបានចំនួន០៣ដង ហើយ គឺយកពីជនជាតិស្បែកខ្មៅ និងជនជាតិវៀតណាម ខ្លួនអត់ស្គាល់ឈ្មោះ [redacted] ថាវី ទេ។ ពេលខ្លួនទៅយកថ្នាំញៀនឲ្យគេម្ដងៗ គេឲ្យលុយខ្លួនចំនួន ២០០ (ពីររយ)ដុល្លារអាមេរិក ទៅ ៣០០ (បីរយ) ដុល្លារអាមេរិក។ ខ្លួនទំនាក់ទំនងជាមួយឈ្មោះ [redacted]លាង តាមរយៈទូរស័ព្ទ ដោយយកថ្នាំញៀនពីម្ដុំស្ទឹងមានជ័យយកទៅគល់ស្ពានជ្រោយចង្វារ។ ពេលសមត្ថកិច្ចឃាត់ខ្លួនបានដកហូតថ្នាំញៀនចំនួន០២កញ្ចប់ (តូច១, ធំ១) ក្រោយមកសមត្ថកិច្ចបាននាំខ្លួនទៅផ្ទះជួលរបស់ខ្លួន ហើយបានឆែករកឃើញថ្នាំញៀនចំនួន០២គីឡូក្រាមបន្ថែមទៀត។ ថ្នាំញៀននេះខ្លួនបានពីឈ្មោះ [redacted] លាង។ រាល់ពេលទៅយកថ្នាំញៀនគឺទៅជួបគ្នានៅគល់ស្ពានស្ទឹងមានជ័យ ដោយអ្នកចាំទទួលពីខ្លួនគឺជនជាតិខ្មែរទាក់ទងគ្នាតាមទូរស័ព្ទ។ រាល់ពេលដែលខ្លួនយកថ្នាំញៀនទៅឲ្យគេគឺមិនបានទូទាត់លុយជាមួយខ្លួនទេ គឺខ្លួនដឹងតែយកថ្នាំញៀនឲ្យគេប៉ុណ្ណោះ។ ពេលដែលខ្លួនយកថ្នាំញៀនគឺឈ្មោះ [redacted] រដ្ឋា ហៅ សឹង, ឈ្មោះ [redacted] សៅ និងឈ្មោះ [redacted] លាង តែងតែទំនាក់ទំនងជាមួយខ្លួនរហូត។ ខ្លួនដឹងថាឈ្មោះ [redacted]លាង ជាអ្នកលាក់ទុកថ្នាំញៀន តែពេលខ្លួនទៅយកថ្នាំញៀនគឺមិនមែនយកពីឈ្មោះ [redacted] លាង ទេ គឺយកពីអ្នកផ្សេង។ ឈ្មោះ [redacted] រដ្ឋា ហៅ សឹង និងឈ្មោះ [redacted]សៅ ជាអ្នកណែនាំខ្លួនឲ្យជួបឈ្មោះ [redacted] លាង ដោយឲ្យខ្លួនជួយដឹកថ្នាំញៀនឲ្យឈ្មោះ [redacted]លាង ដើម្បីបានទទួលប្រាក់ឈ្នួលខ្លះ៖ ប៉ុន្តែខ្លួនអត់ស្គាល់ឈ្មោះ [redacted]លាង ទេ រហូតដល់ពេលដឹកជញ្ជូនទើបខ្លួនស្គាល់ឈ្មោះ [redacted] លាង តាមរយៈទូរស័ព្ទដៃ។ ឈ្មោះ [redacted] រដ្ឋា ហៅ សឹង និងឈ្មោះ [redacted]សៅ គាត់បានដឹងពីការដឹកជញ្ជូនថ្នាំ



Scanned with CamScanner

ញៀននេះ។ ខ្លួនអត់ដឹងថាឈ្មោះ [redacted] លាង ឲ្យលុយឈ្មោះ [redacted] ង៉ា ហៅ សឹង និងឈ្មោះ [redacted] សៅ ចំនួនប៉ុន្មានទេ។

-ជនជាប់ចោទឈ្មោះ [redacted] ង៉ា ហៅ សឹង បានឆ្លើយថា៖ ខ្លួនស្គាល់ឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា ព្រោះនៅស្រុកភូមិជាមួយគ្នា ខ្លួនទំនាក់ទំនងយកលេខទូរស័ព្ទរបស់ឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា ទៅឲ្យឈ្មោះ [redacted] លាង ដើម្បីឲ្យឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា យកគ្រឿងញៀនលក់ឲ្យឈ្មោះ [redacted] លាង។ រាល់ពេលដែលឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា យកថ្នាំញៀនទៅឲ្យគេខ្លួនតែងតែទំនាក់ទំនងជាមួយឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា ហើយប្រាប់គាត់ថាធ្វើការងារឲ្យបានល្អកុំឲ្យបាត់បង់របស់គេ។ ចំពោះឈ្មោះ បាឡូ និងឈ្មោះ បាបា គឺជាឈ្មោះហៅក្រៅដែលជាអ្នកយកថ្នាំមកឲ្យឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា។ ឈ្មោះ យ៉ាំង លាង ជាអ្នកទំនាក់ទំនង និងជាអ្នកយកលេខទូរស័ព្ទរបស់ឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា ឲ្យទៅឈ្មោះ បាឡូ ហៅ បាបា។ ខ្លួនប្រាប់ឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា ឲ្យជួយយកថ្នាំញៀនឲ្យគេ ហើយឈ្មោះ [redacted] លាង ប្រាប់ថាក្នុងថ្នាំ០១គីឡូក្រាមឲ្យលុយចំនួន ៥០ (ហាសិប) ដុល្លារអាមេរិក។ ឈ្មោះ [redacted] សៅ ជាអ្នកទំនាក់ទំនងយកលេខទូរស័ព្ទរបស់ឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា មកឲ្យខ្លួន។ ឈ្មោះ [redacted] ារី ខ្លួនអត់ស្គាល់ទេ តែឈ្មោះ [redacted] លាង ប្រាប់ខ្លួនថាឈ្មោះ [redacted] ថារី ធ្លាប់បានទិញថ្នាំញៀនពីឈ្មោះ យ៉ាំង លាង ម្តង០៥គីឡូក្រាម ថែមទាំងបានណែនាំឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា ឲ្យស្គាល់ឈ្មោះ [redacted] ថារី។ ខ្លួនអត់ដឹងថាថ្នាំញៀននៅបន្ទប់របស់ឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា មានប៉ុន្មានគីឡូក្រាមទេ ខ្លួនគ្រាន់តែដឹងថាឈ្មោះ [redacted] លាង ជាអ្នកបញ្ជាឲ្យឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា យកថ្នាំញៀនទៅទុកនៅបន្ទប់គាត់។ ឈ្មោះ [redacted] លាង គាត់ចេះនិយាយភាសា អង់គ្លេស និងជាអ្នកទំនាក់ទំនងការងារជាមួយជនបរទេស។ រាល់ពេលដែលឈ្មោះ [redacted] លាង ទំនាក់ទំនងជាមួយឈ្មោះ បាឡូ ជាភាសាអង់គ្លេសខ្លួនស្តាប់មិនបានទេតែខ្លួនដឹងតាមរយៈកាយ វិការរបស់ឈ្មោះ [redacted] លាង តែប៉ុណ្ណោះ។ ឈ្មោះ [redacted] លាង និយាយជាមួយខ្លួនជាភាសាខ្មែរ ចំពោះលុយអ្នកទទួលបានថ្នាំញៀនគឺវេលុយតាមសេវាកម្មវីង វេលុយម្តងចំនួន ៥.០០០$ (ប្រាំពាន់) ដុល្លារអាមេរិក ទៅ ១០.០០០$ (មួយម៉ឺន)ដុល្លារអាមេរិក។

-ជនជាប់ចោទឈ្មោះ [redacted] សៅ បានឆ្លើយថា៖ កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៤ ឈ្មោះ [redacted] ង៉ា បានសុំលេខទូរស័ព្ទរបស់ឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា ពីខ្លួនយកទៅឲ្យឈ្មោះ [redacted] លាង។ ខ្លួនអត់ដឹងរឿងអ្វីទេ ហើយក៏អត់ដែលបានលុយដែរគ្រាន់តែបានហូបបាយជាមួយឈ្មោះ [redacted] លាង តែប៉ុណ្ណោះ។ ពេលឈ្មោះ [redacted] ង៉ា ហៅ សឹង សុំលេខទូរស័ព្ទរបស់ឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា គាត់បានប្រាប់ខ្លួនថាដើម្បីសួរសុខទុក្ខ និងសុំលុយគាត់ចាយតែប៉ុណ្ណោះ។ ខ្លួនស្គាល់ ឈ្មោះ [redacted] លាង ក្រោយពេលដែលខ្លួនជាប់ពន្ធនាគាររយៈពេល០២ទៅ០៣ខែ ដោយគាត់ ឧស្សាហ៍ហៅខ្លួនទៅហូបបាយជាមួយគាត់ព្រោះគាត់មានចុងភៅដាំស្ល។ ឈ្មោះ [redacted] លាង មានទូរស័ព្ទប្រើប្រាស់ផ្ទាល់ខ្លួន។

-ជនជាប់ចោទឈ្មោះ [redacted] SAMUEI ហៅ បាឡូ បានឆ្លើយថា៖ ខ្លួនធ្លាប់ឃើញឈ្មោះ [redacted] ង៉ា ហៅ សឹង និងឈ្មោះ [redacted] សៅ ព្រោះស្នាក់នៅក្នុងបន្ទប់ជាមួយខ្លួន តែខ្លួនអត់ដែលហៅគាត់និងនិយាយជាមួយគាត់ទេ។ ខ្លួនមានឈ្មោះ SAMUEI ហើយខ្លួនអត់

ដឹងថាអ្នកផ្សេងហៅខ្លួនថាឈ្មោះ បាឡូ ទេ។ ទាក់ទងនឹងរឿងហេតុកើតឡើងមកនេះខ្លួនអត់ដឹងរឿងហេតុអ្វីទេ ខ្លួនអត់ស្គាល់ឈ្មោះ [redacted] លាង តែបើឃើញមុខស្គាល់ តែអត់ដែលបាននិយាយជាមួយគ្នាទេ ហើយក៏អត់ដែលហូបបាយជាមួយគ្នាដែរ។ ឈ្មោះ បាឡូ នេះមិនមែនជាឈ្មោះរបស់ខ្លួនទេ ខ្លួនមិនដឹងហេតុអ្វីបានជាគេហៅឈ្មោះ បាឡូ នេះទេ ទើបតែឮសមត្ថកិច្ចហៅឈ្មោះខ្លួនថា បាឡូ។ BENTO ជាមិត្តភក្តិរបស់ខ្លួន ខ្លួនអត់ដែលនិយាយជាមួយឈ្មោះ យ៉ាំង លាង ទេ ហើយខ្លួនក៏អត់ដឹងថាឈ្មោះ [redacted] លាង ចេះនិយាយភាសាអង់គ្លេសដែរ។ ខ្លួនហូបបាយតែជាមួយឈ្មោះ BENTO ទេ ខ្លួនមិនមានភាពស្និតស្នាលជាមួយអ្នករួមបន្ទប់ទេ ហើយក៏មិនមានទំនាស់ជាមួយអ្នកនៅក្នុងបន្ទប់ដែរ។

-ជនជាប់ចោទឈ្មោះ [redacted] BENTO បានឆ្លើយថា៖ ខ្លួនអត់ស្គាល់ឈ្មោះ [redacted] លាង តែខ្លួនដឹងថាគាត់ជាជនជាតិវៀតណាមស្នាក់នៅបន្ទប់ជាមួយខ្លួន។ ខ្លួនអត់ចេះភាសាខ្មែរ អត់ចេះភាសាវៀតណាម ហើយក៏អត់ដែលបាននិយាយជាមួយជនជាតិវៀតណាមទេ។ មុនពេល មានរឿងប៉ុន្មានថ្ងៃខ្លួនធ្លាប់បានឈ្លោះគ្នាជាមួយឈ្មោះ [redacted] វង្សា ហៅ សឹង ដោយសារតែឈ្មោះ [redacted] វង្សា ហៅ សឹង ជាន់ជើងខ្លួន។ ពេលជាប់ពន្ធនាគារខ្លួនអត់ដែលបានទូរស័ព្ទទៅក្រៅទេ ខ្លួន ជាប់ពន្ធនាគារ ២៧ឆ្នាំ ខ្លួនអត់ដែលមានទំនាក់ទំនងជាមួយជនជាតិវៀតណាមទេ។ ពេលខ្លួនចង់និយាយឆ្មាំពន្ធនាគារហៅអ្នកទោសដែលនៅបន្ទប់ផ្សេងមកនិយាយបកប្រែឲ្យខ្លួន។ ខ្លួនញ៉ាំអាហារតែជាមួយឈ្មោះ OKEKE អាហារទាំងនេះគឺចំអិនខ្លួនឯងមិនដែលបានទៅទិញអាហារពី ខាងក្រៅមកទេ តែពេលខ្លះមានខាងអង្គការបានយកម្ហូបអាហារមកឲ្យខ្លួន។ ខ្លួនមិនដែលហូប បាយជាមួយឈ្មោះ [redacted] សៅ និងឈ្មោះ [redacted] វង្សា ហៅ សឹង ទេហើយក៏មិនមានទំនាក់ទំនងអ្វីជាមួយឈ្មោះ [redacted] លាង ផងដែរ។

-ជនជាប់ចោទឈ្មោះ [redacted] លាង បានឆ្លើយថា៖ ខ្លួនស្គាល់ឈ្មោះ OKEKE, ឈ្មោះ [redacted] វង្សា ហៅ សឹង, ឈ្មោះ [redacted] សៅ និងឈ្មោះ BENTO តែអត់ស្គាល់ឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា ទេ។ ខ្លួនធ្លាប់អន់ចិត្តជាមួយឈ្មោះ [redacted] សៅ និងឈ្មោះ [redacted] វង្សា ហៅ សឹង ព្រោះក្រោយពេលដែលខ្លួនជាប់ពន្ធនាគារចំនួន០២ខែអ្នកទាំងពីរនាក់ចេះសួរខ្លួនរកម៉ូយទិញគ្រឿងញៀន។ ខ្លួនអត់ចេះភាសាអង់គ្លេសទេ ចំពោះជនបរទេសពីរនាក់នេះគឺខ្លួនមិនចូលចិត្តទេព្រោះពិបាកនិយាយគ្នាខ្លួនអត់ដែលហូបបាយជាមួយជនបរទេសទាំងពីរនាក់នេះទេ។ ខ្លួនអត់មានទូរស័ព្ទប្រើប្រាស់ទេ ចំពោះទូរស័ព្ទម៉ាក Nចុចពិល មិនដឹងជារបស់អ្នកណាទេ ខ្លួនធ្លាប់ប្រើទូរស័ព្ទរបស់ពន្ធនាគារ ទូរស័ព្ទទៅប្រទេសវៀតណាមដើម្បីជួបប្រពន្ធកូនដើម្បីសុំលុយរយៈពេល០១ខែម្តង។ ខ្លួនអត់ ធ្លាប់និយាយជាមួយជនបរទេស០២នាក់នេះទេ ហើយខ្លួនក៏មិនធ្លាប់និយាយលេងជាមួយឈ្មោះ [redacted] វង្សា ហៅ សឹង។ កន្លងមកឈ្មោះ [redacted] វង្សា ហៅ សឹង និងឈ្មោះ [redacted] សៅ ធ្លាប់ទំនាក់ទំនងខ្លួនសួររកអ្នកទិញថ្នាំញៀន (រកម៉ូយទិញ)។

-លោក [redacted] សុភាព ជាមន្ត្រីនគរបាលយុត្តិធម៌បានឆ្លើយថា៖ ខ្លួនជាអ្នកចុះប្រតិបត្តិការណ៍ជាមួយសមត្ថកិច្ចខណ្ឌឬស្សីកែវ។ ឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា គាត់បានសហការណ៍ជាមួយកម្លាំងសមត្ថកិច្ចដោយបាននាំសមត្ថកិច្ចទៅបន្ទប់ឆែកឆេរឃើញថ្នាំញៀនចំនួន០២គីឡូក្រាម និង



Scanned with CamScanner

ថ្នាំគ្រាប់។ បន្ទាប់មកឈ្មោះ [redacted] ធូវ៉ា ហៅ ត្រា បានទូរស័ព្ទទំនាក់ទំនងទៅឈ្មោះ សួន សៅ, ឈ្មោះ [redacted] វង្សា ហៅ សឹង និងឈ្មោះ [redacted] លាង នៅក្នុងពន្ធនាគារព្រៃស ហើយសមត្ថកិច្ចក៏ចុះទៅពន្ធនាគារព្រៃសហើយនាំជនជាប់ចោទទាំងបីនាក់មកសាកសួរ ទើបដឹងថាមានមេក្លោងថ្នាំញៀនចំនួន០៣នាក់ទៀតជាជនបរទេស ក្រោយពីសួរចម្លើយជនជាប់ចោទរួចហើយជនជាប់ចោទក៏បាននាំកម្លាំងសមត្ថកិច្ចទៅយកគ្រឿងញៀនប្រភេទ WY បានចំនួន ១៧សុង។

-ក្រឡាបញ្ជីអានកំណត់ហេតុធ្វើតេស្តពិសោធន៍បឋម និងវេចខ្ចប់វត្ថុតាងលេខ ០៥៣/១៦ ក.ប.គ.ញ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦ របស់ការិយាល័យបទល្មើសគ្រឿងញៀន បានបញ្ជាក់ថា គ្រឿងញៀនខុសច្បាប់មានសណ្ឋានជា ក្រាមពណ៌សថ្លាចំនួន ២១កញ្ចប់ធំ ដែលមានទម្ងន់សុទ្ធសរុប ៣០១២,៩g (បីពាន់សូន្យរយដប់ពីរក្បៀសប្រាំបួនក្រាម) និងថ្នាំគ្រាប់ពណ៌ផ្កាឈូក ចំនួន ៥១៨ កញ្ចប់ ដែលមានទម្ងន់សុទ្ធសរុប ១០៤១០,៧g (មួយម៉ឺនសូន្យពាន់បួនរយដប់ក្បៀសប្រាំពីរក្រាម) ដែលបានដកហូតពីឈ្មោះ [redacted] ធូវ៉ា ហៅ ត្រា។

-ក្រឡាបញ្ជីអានលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ៦៣១៤/១៦ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ របស់មន្ទីរពិសោធន៍នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានសន្និដ្ឋានថា៖

សំណាកទី១ : ជាគ្រឿងញៀនប្រភេទក្រាមម្សៅ ឈ្មោះ មេតំហ្វេតាមីន (ហៅក្រៅអាយ ឬម៉ាទឹកកក ឬអាយ) ដែលមានកម្រិត ភាពសុទ្ធ ៨១,៩៩% នៃទម្ងន់សរុប។

សំណាកទី២ : ជាគ្រឿងញៀនប្រភេទគ្រាប់ ឈ្មោះ មេតំហ្វេតាមីន (ហៅក្រៅ យ៉ាបា ឬថ្នាំឆ្កួត) ដែលមានកម្រិតភាពសុទ្ធ ១៦,៦០% នៃទម្ងន់សរុប។

*មេតំហ្វេតាមីន ស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា។

-ក្រឡាបញ្ជីអានកំណត់ហេតុទទួលវត្ថុចាប់យកលេខ ៣៨៣ អ.យ.ធ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញរួមមាន៖

ក.ស្រោមសំបុត្រពណ៌សបិទផ្លាស្ទិកជិតមានសរសេរថា ថ្នាំគ្រាប់ពណ៌ផ្កាឈូកមានទម្ងន់ថ្នាំសុទ្ធ ៣.០៤ ក្រាម ច្រកចូលក្នុងកូនថង់តូចៗចំនួន ៣។

ខ.ស្រោមសំបុត្រពណ៌សបិទផ្លាស្ទិកជិតមានសរសេរថា ក្រាមពណ៌សថ្លាមានទម្ងន់ជាក្រាមសុទ្ធ ៨.០២ ក្រាម ច្រកចូលក្នុងកូនថង់តូចៗចំនួន៣។

គ.ទូរស័ព្ទដៃពីរគ្រឿងម៉ាកណូគាអិនចុចពិលពណ៌ខ្មៅលាយខៀវមួយគ្រឿង និងម៉ាកសាំសុងពណ៌សមួយគ្រឿង។

ឃ.ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនមួយគ្រឿង។

ង.ថង់ពណ៌ស មានដាក់កូនសៀវភៅពណ៌ខ្មៅតូចចំនួន០១, កាសទូរស័ព្ទអាយហ្វូនចំនួន០១, ឡាមសម្រាប់កាត់មួយប្រអប់ និងកូនម៉ូឌឹមតូចពណ៌ខ្មៅចំនួន០១ និងឯកសារផ្សេងៗ។

ច.ថង់ពណ៌ស មានកូនថង់តូចសម្រាប់ដាក់គ្រឿងញៀន។

ឆ.ប្រអប់ពណ៌ប្រផេះមានអក្សរដាក់ថា Pedro ចំនួន ១។

ជ.កេសដែកដាក់គ្រឿងញៀនពណ៌ផ្ទៃមេឃបិទជិត ដោយគណៈកម្មាការត្រួតពិនិត្យវត្ថុតាងចំនួន១។

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំថា៖ ក្រោយពីបានសួរដេញដោលក្នុងពេលសវនាការរួចមកឃើញថា ជនជាប់ចោទឈ្មោះ[redacted] សៅ, ឈ្មោះ[redacted] វង្ងា ហៅ សឹង និងឈ្មោ[redacted] ធូរ៉ា ហៅ ត្រា បានសហការណ៍យ៉ាងល្អជាមួយសមត្ថកិច្ច និងតុលាការ ចំពោះជនជាប់ចោទជាជនបរទេសចំនួន០៣នាក់ មានឈ្មោះ[redacted] លាង, ឈ្មោ[redacted] SAMUEL និងឈ្មោះ [redacted]BENTO មិនបានសហការណ៍ជាមួយតុលាការទេ តែបើតាម ការរាយការណ៍របស់សមត្ថកិច្ចនៅក្នុងបន្ទប់សវនាការសុំតម្កល់ការចោទប្រកាន់ទុកនៅដដែល តែសុំលោកក្រុមប្រឹក្សាជំនុំជម្រះពិចារណាលើជនជាប់ចោទចំនួន០៣នាក់ជាជនជាតិខ្មែរ ដែលបាន សហការណ៍ល្អជាមួយសមត្ថកិច្ចនិងតុលាការ ចំណែកឯជនជាប់ចោទចំនួន ០៣នាក់ទៀតជាជនបរទេសសុំឲ្យតុលាការផ្ដន្ទាទោសតាមច្បាប់។

-លោក[redacted]ឡាយយី មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា បានធ្វើសេចក្ដីសន្និដ្ឋានការពារថា៖ កូនក្ដីខ្លួនត្រូវបានសមត្ថកិច្ចឃាត់ខ្លួនជាក់ស្ដែង កូនក្ដីខ្លួនបានសារភាពដោយស្មោះត្រង់ និងសហការណ៍ជាមួយសមត្ថកិច្ចបាននាំសមត្ថកិច្ចទៅយកថ្នាំញៀននៅបន្ទប់ជួលរបស់ខ្លួនចំនួន០២គីឡូក្រាម បន្ទាប់មកបាននាំសមត្ថកិច្ចទៅចាប់យកជនពាក់ព័ន្ធចំនួន០២នាក់ពីពន្ធនាគារព្រៃសមានឈ្មោះ[redacted]វង្ងា និងឈ្មោះ [redacted] សៅ។ ក្រោយមកទៀតបានសហការណ៍ជាមួយសមត្ថកិច្ចទៅយកថ្នាំញៀនបានចំនួន ១៧កញ្ចប់ និងបង្ហាញជនពាក់ព័ន្ធជាមេក្លោងទៀតផង ហេតុនេះសុំលោកក្រុមប្រឹក្សាមេត្តាផ្ដន្ទាទោសកូនក្ដីខ្លួនត្រឹមអប្បបរិមានៃទោសតាមមាត្រា៤០ និងមាត្រា៣២ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

-លោកស្រី[redacted] សុខា មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សៅ និងឈ្មោះ [redacted] វង្ងា បានធ្វើសេចក្ដីសន្និដ្ឋានការពារថា៖ កន្លងមកនៅសមត្ថកិច្ចក៏ដូចជានៅចំពោះមុនអង្គ សវនាការកូនក្ដីខ្លួនឈ្មោ[redacted]សៅ គ្រាន់តែបានផ្ដល់លេខទូរស័ព្ទទៅឈ្មោះ [redacted] វង្ងា ឯឈ្មោះ [redacted] វង្ងា បានយកលេខទូរស័ព្ទរបស់ឈ្មោ[redacted]ធូរ៉ា ហៅ ត្រា ទៅឲ្យឈ្មោ[redacted]លាង បន្តទៀត ឈ្មោះ [redacted] សៅ អត់បានទទួលផលប្រយោជន៍អ្វីទេ ហើយក៏មិនដឹងថាឈ្មោះ [redacted] វង្ងា យក លេខទូរស័ព្ទទៅឲ្យឈ្មោះ [redacted]លាង ដើម្បីធ្វើអ្វីដែរ។ កូនក្ដីខ្លួនឈ្មោ[redacted]វង្ងា និងឈ្មោ[redacted] សៅ បានសហការណ៍ជាមួយសមត្ថកិច្ចរហូតដល់ចាប់បានជនបរទេសចំនួន០៣នាក់ទៀត និងដកហូតថ្នាំញៀនមួយចំនួនទៀត ដូចលោកសមត្ថកិច្ចក៏បានលើកឡើងក្នុងពេលសវនាការនេះដែរ ហេតុនេះសុំក្រុមប្រឹក្សាមេត្តាលើកលែងចោទប្រកាន់ដល់កូនក្ដីខ្លួនឈ្មោ[redacted] វង្ងា ចំណែក ឈ្មោះ [redacted] វង្ងា សុំលោកក្រុមប្រឹក្សាមេត្តាបន្ធូរបន្ថយទោសដល់គាត់ផងចុះ។

-លោក [redacted] ទីលីន មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ OKEKE [redacted] SAMUEL និងឈ្មោះ [redacted] BENTO បានធ្វើសេចក្ដីសន្និដ្ឋានការពារថា៖ ឆ្លងតាមការស្រាវជ្រាវរបស់សមត្ថកិច្ចរហូតដល់ចាប់ខ្លួនកូនក្ដីខ្លួនទាំងពីរនាក់ឃើញថា គាត់ទាំងពីរនាក់នេះពុំមានការទាក់ទងក្នុងការជួញដូរថ្នាំញៀននេះទេ គ្រាន់តែជាការទំលាក់កំហុសរបស់ឈ្មោះ [redacted] វង្ងា



Scanned with CamScanner

និងឈ្មោះ[redacted]សៅ មកឲ្យកូនក្តីខ្លួនដោយសារគាត់មានទំនាស់ជាមួយកូនក្តីខ្លួន ពុំមានភស្តុតាងដាក់បន្ទុកទេព្រោះកូនក្តីខ្លួនពុំបានទូរស័ព្ទចូលមកទេ។ចំណុចនេះជាវិមតិសង្ស័យលើកូនក្តីខ្លួន ដូច្នេះសុំលោកក្រុមប្រឹក្សាមេត្តាលើកលែងចោទប្រកាន់ដល់កូនក្តីខ្លួនទាំងពីរនាក់ឲ្យមានសេរីភាពវិញ។

-លោក [redacted] វណ្ណរ៉េត មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] BENTO បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ខ្លួនសុំរក្សាការសន្និដ្ឋានរបស់សហការីរបស់ខ្លួនគឺលោក គង់ ទីលីន ទាំងស្រុងដោយសុំលើកលែងចោទប្រកាន់កូនក្តីខ្លួនឲ្យមានសេរីភាពវិញ។

-លោក[redacted]គ្រុយ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ថាវី ហៅ [redacted] ក៉ាវី បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ក្នុងពេលសវនាការនេះឃើញថាពុំមានពាក់ព័ន្ធនឹងកូនក្តីខ្លួន ទេព្រោះគាត់ជាជនបង្កប់របស់សមត្ថកិច្ចព្រមទាំងមានឯកសារជូនមកតុលាការរួចហើយ សុំលោកក្រុមប្រឹក្សាមេត្តាពិចារណាលើបាយការណ៍ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៦ គាត់បានសហការណ៍ជាមួយមន្ទីរប្រឆាំងគ្រឿងញៀន ហេតុនេះសុំលោកក្រុមប្រឹក្សាជំនុំជម្រះមេត្តា បញ្ឈប់ការចាប់ខ្លួនកូនក្តីខ្លួន និងសុំឲ្យកូនក្តីខ្លួនឈ្មោះ[redacted]ថាវី ហៅ[redacted] ក៉ាវី រួចផុតពីបទចោទ ប្រកាន់។

-លោក [redacted] មុន្នីជាតិ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted] លាង បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ក្រោយពីការសួរដេញដោលនាពេលសវនាការមក ឃើញថាការស៊ើបអង្កេតនេះមិនទាន់បានស៊ីជំរៅនោះទេ ព្រោះថាទូរស័ព្ទនោះដកហូតមកពីក្នុងបន្ទប់ដេកដែលមានគ្នាហូតដល់ជាង៦០នាក់ឯណោះ ចំណែកថ្នាំញៀនមិនបានទទួលពីកូនក្តីរបស់ខ្លួនទេ ម្យ៉ាងទៀតអ្នកទាំងបីនាក់នេះធ្លាប់មានទំនាស់ជាមួយគ្នាទៀតផង ហើយតុលាការដាក់ទោសកូនក្តីខ្លួនមិនត្រឹមត្រូវទេ។ ហេតុនេះសុំលើកលែងចោទប្រកាន់ដល់កូនក្តីខ្លួនឈ្មោះ យ៉ាំង លាង។

-ជនជាប់ចោទឈ្មោះ[redacted]ផូ៉ា ហៅ ត្រា បាននិយាយសំដីចុងក្រោយថា៖ សុំឲ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួនផង។

-ជនជាប់ចោទឈ្មោះ[redacted] វង្សា បាននិយាយសំដីចុងក្រោយថា៖ សុំឲ្យតុលាការលើកលែងចោទប្រកាន់ដល់ខ្លួនផង។

-ជនជាប់ចោទឈ្មោះ [redacted] សៅ បាននិយាយសំដីចុងក្រោយថា៖ សុំឲ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួនផង។

-ជនជាប់ចោទឈ្មោះ [redacted] SAMUEL បាននិយាយសំដីចុងក្រោយថា៖ សុំឲ្យតុលាការជួយរកយុត្តិធម៌ដល់ខ្លួនផង។

-ជនជាប់ចោទឈ្មោះ[redacted] BENTO បាននិយាយសំដីចុងក្រោយថា៖ សុំឲ្យតុលាការដោះលែងខ្លួនឲ្យមានសេរីភាព។

-ជនជាប់ចោទឈ្មោះ [redacted] លាង បាននិយាយសំដីចុងក្រោយថា៖ ឲ្យតុលាការដោះលែងខ្លួនឲ្យមានសេរីភាព។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ



Scanned with CamScanner

-ក្រោយពីបានពិនិត្យលើសំណុំរឿងឯកសារភស្តុតាងនានា

-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់រួចហើយ

## សំអាងហេតុ

១-តាមដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ២៦២៦ "ច".ដ.ជ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ឃើញថា ជនជាប់ចោទឈ្មោះ[redacted]រ៉ា ហៅ ត្រា ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ, ឈ្មោះ[redacted]លាង ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិវៀតណាម, ឈ្មោះ[redacted]សៅ ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] វង្ហា ហៅ ស៊ឹង ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] SAMUEL ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិ NIGERIAN, ឈ្មោះ [redacted] BENTO ភេទប្រុស អាយុ៤១ឆ្នាំ ជនជាតិ BISSAU និងឈ្មោះ ថាវ ថាវី ហៅ ឡុង ភ៉ាវី ភេទប្រុស កើតឆ្នាំ១៩៨៣ ជាតិខ្មែរ ត្រូវបានបញ្ជូនមកជម្រះពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចចំណតរថយន្តក្រុងក្រុមហ៊ុនអង្គរអ៊ិចប្រេស ផ្លូវជាតិលេខ៥ ក្រុម១៤ ភូមិផ្សារតូច សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ និងបន្ទប់ជួលលេខ៧៧ ភូមិ៤ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ថ្ងៃទី២៩ ខែកុម្ភៈ និងថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-តាមរបាយការណ៍សំយោគលេខ ០៥៣/១៦ ក.ប.គ.ញ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ របស់ការិយាល័យប្រឆាំងគ្រឿងញៀនបានបញ្ជាក់ថា ឈ្មោះ[redacted]រ៉ា ហៅ ត្រា ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ, ឈ្មោះ[redacted]លាង ភេទប្រុស អាយុ ៣៧ឆ្នាំ ជនជាតិវៀតណាម, ឈ្មោះ [redacted] សៅ ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] វង្ហា ហៅ ស៊ឹង ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] SAMUEL ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិ NIGERIAN, ឈ្មោះ [redacted]BENTO ភេទប្រុស អាយុ៤១ឆ្នាំ ជនជាតិ BISSAU បានធ្វើសកម្មភាពទិញ លក់ដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចចំណតរថយន្តក្រុងក្រុមហ៊ុនអង្គរអ៊ិចប្រេស ផ្លូវជាតិលេខ៥ ក្រុម១៤ ភូមិផ្សារតូច សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ និងបន្ទប់ជួលលេខ៧៧ ភូមិ៤ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ថ្ងៃទី២៩ ខែកុម្ភៈ និងថ្ងៃទី ០១ ខែមីនា ឆ្នាំ២០១៦។

៣-តាមចម្លើយជនជាប់ចោទឈ្មោះ[redacted]រ៉ា ហៅ ត្រា បានឆ្លើយសារភាពថា ខ្លួនយកថ្នាំញៀនទៅឲ្យម៉ូយតាមការបញ្ជារបស់ឈ្មោះ [redacted]វង្ហា ហៅ ស៊ឹង ដែលទូរស័ព្ទមកខ្លួន ហើយ ឈ្មោះ [redacted] វង្ហា ហៅ ស៊ឹង ប្រាប់ឲ្យខ្លួនធ្វើការងារនេះតាមរយៈឈ្មោះ យ៉ាំង លាង ដោយឲ្យខ្លួនដឹកថ្នាំញៀនទៅឲ្យម៉ូយ ខ្លួនយកថ្នាំញៀននេះបានចំនួន០៣ដងហើយ គឺយកពីជនជាតិស្បែកខ្មៅ និងជនជាតិវៀតណាម។ ពេលខ្លួនទៅយកថ្នាំញៀនឲ្យគេម្តងៗគេឲ្យលុយខ្លួនចំនួន ២០០$ (ពីររយ)ដុល្លារអាមេរិក ទៅ ៣០០$ (បីរយ)ដុល្លារអាមេរិក។ ខ្លួនទំនាក់ទំនងជាមួយឈ្មោះ [redacted] លាង តាមរយៈទូរស័ព្ទដោយយកថ្នាំញៀនពីម៉ុស្ទឹងមានជ័យយកទៅគល់ស្ពានជ្រោយចង្វារ។ ថ្នាំញៀននេះខ្លួនបានពីឈ្មោះ [redacted]លាង។ ពេលដែលខ្លួនយកថ្នាំញៀនទៅឲ្យម៉ូយគឺឈ្មោះ [redacted] វង្ហា ហៅ

ថ្នាំគ្រាប់។ បន្ទាប់មកឈ្មោះ[redacted]៉ា ហៅ ត្រា បានទូរស័ព្ទទំនាក់ទំនងទៅឈ្មោះ[redacted]សៅ, ពេ
[redacted] វង្ហា ហៅ សឹង និងឈ្មោះ[redacted] លាង នៅក្នុងពន្ធនាគារព្រៃស ហើយសមត្ថកិច្ចកំ
ទៅពន្ធនាគារព្រៃសហើយនាំជនជាប់ចោទទាំងបីនាក់មកសាកសួរ ទើបដឹងថាមានមេក្លោង
ញៀនចំនួន០៣នាក់ទៀតជាជនបរទេស ក្រោយពីសួរចម្លើយជនជាប់ចោទរួចហើយជនជាប់ចោ
បាននាំកម្លាំងសមត្ថកិច្ចទៅយកគ្រឿងញៀនប្រភេទ WY បានចំនួន ១៧សុង។

-ក្រឡាបញ្ជីអានកំណត់ហេតុធ្វើតេស្តពិសោធន៍បឋម និងវេចខ្ចប់វត្ថុតាងលេខ ០៥៣/១
ក.ប.គ.ញ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦ របស់ការិយាល័យបទល្មើសគ្រឿងញៀន បានបញ្ជា
ថា គ្រឿងញៀនខុសច្បាប់មានសណ្ឋានជា ក្រាមពណ៌សថ្លាចំនួន ២១កញ្ចប់ធំ ដែលមានទម្ងន់សុទ្ធ
សរុប ៣០១២,៩g (បីពាន់សូន្យរយដប់ពីរក្បៀសប្រាំបួនក្រាម) និងថ្នាំគ្រាប់ពណ៌ផ្កាឈូក ចំនួន
៥១៨ កញ្ចប់ ដែលមានទម្ងន់សុទ្ធសរុប ១០៤១០,៧g (មួយម៉ឺនសូន្យពាន់បួនរយដប់
ក្បៀសប្រាំពីរក្រាម) ដែលបានដកហូតពីឈ្មោះ[redacted]៉ា ហៅ ត្រា។

-ក្រឡាបញ្ជីអានលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ៦៣១៤/១៦ម.ព.អ.ជ.ប.គ.ញ
ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ របស់មន្ទីរពិសោធន៍នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធ
ប្រឆាំងគ្រឿងញៀនបានសន្និដ្ឋានថា៖

សំណាកទី១ : ជាគ្រឿងញៀនប្រភេទក្រាមម្សៅ ឈ្មោះ មេតំហ្វេតាមីន (ហៅក្រៅអាយ
ឬម៉ាទឹកកក ឬអាយ) ដែលមានកម្រិត ភាពសុទ្ធ ៨១,៩៩% នៃទម្ងន់សរុប។

សំណាកទី២ : ជាគ្រឿងញៀនប្រភេទគ្រាប់ ឈ្មោះ មេតំហ្វេតាមីន (ហៅក្រៅ យ៉ាបា
ឬថ្នាំឆ្កួត) ដែលមានកម្រិតភាពសុទ្ធ ១៦,៦០% នៃទម្ងន់សរុប។

*មេតំហ្វេតាមីន រាស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែង
លម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា។

-ក្រឡាបញ្ជីអានកំណត់ហេតុទទួលវត្ថុចាប់យកលេខ ៣៨៣ អ.យ.ធ ចុះថ្ងៃទី០៤ ខែមីនា
ឆ្នាំ២០១៦ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញរួមមាន៖

ក.ស្រោមសំបុត្រពណ៌សបិទផ្លាស្ទិកជិតមានសរសេរថា ថ្នាំគ្រាប់ពណ៌ផ្កាឈូកមាន
ទម្ងន់ថ្នាំសុទ្ធ ៣.០៤ ក្រាម ប្រកចូលក្នុងកូនថង់តូចៗចំនួន ៣។

ខ.ស្រោមសំបុត្រពណ៌សបិទផ្លាស្ទិកជិតមានសរសេរថា ក្រាមពណ៌សថ្លាមាន
ទម្ងន់ជាក្រាមសុទ្ធ ៨.០២ ក្រាម ប្រកចូលក្នុងកូនថង់តូចៗចំនួន៣។

គ.ទូរស័ព្ទដៃពីរគ្រឿងម៉ាកណូគាអិនចុចពិលពណ៌ខ្មៅលាយខៀវមួយគ្រឿង និង
ម៉ាកសាំសុងពណ៌សមួយគ្រឿង។

ឃ.ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនមួយគ្រឿង។

ង.ថង់ពណ៌ស មានដាក់កូនសៀវភៅពណ៌ខ្មៅតូចចំនួន០១, កាសទូរស័ព្ទអាយ
ហ្វូនចំនួន០១, ឡាមសម្រាប់កាត់មួយប្រអប់ និងកូនម៉ូឌឹមតូចពណ៌ខ្មៅចំនួន០១ និងឯកសារ
ផ្សេងៗ។

ច.ថង់ពណ៌ស មានកូនថង់តូចសម្រាប់ដាក់គ្រឿងញៀន។

សឹង, ឈ្មោះ [redacted] សៅ និងឈ្មោះ [redacted] លាង តែតែងទំនាក់ទំនងជាមួយខ្លួន ហេតុ។ ខ្លួនដឹងថាឈ្មោះ [redacted] លាង ជាអ្នកលាក់ទុកថ្នាំញៀន ឈ្មោះ [redacted] វង្ហា ហៅ សឹង និង ឈ្មោះ [redacted] សៅ ជាអ្នកណែនាំខ្លួនឲ្យជួបឈ្មោះ [redacted] លាង ដោយឲ្យខ្លួនជួយដឹកថ្នាំញៀន ឲ្យឈ្មោះ [redacted] លាង ដើម្បីបានទទួលប្រាក់ឈ្នួលខ្លះ ខ្លួនស្គាល់ឈ្មោះ [redacted] លាង តាមរយៈទូរស័ព្ទដៃ។ ឈ្មោះ [redacted] វង្ហា ហៅ សឹង និងឈ្មោះ [redacted] សៅ គាត់បានដឹងពីការដឹកជញ្ជូនថ្នាំ ញៀននេះ។

៤-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] វង្ហា ហៅ សឹង បានឆ្លើយសារភាពថា៖ ខ្លួនទំនាក់ទំនងយកលេខទូរស័ព្ទរបស់ឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា ទៅឲ្យឈ្មោះ [redacted] លាង ដើម្បីឲ្យឈ្មោះ ឌី ធូរ៉ា ហៅ ត្រា យកគ្រឿងញៀនលក់ឲ្យឈ្មោះ យ៉ាំង លាង។ រាល់ពេលដែលឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា យកថ្នាំញៀនទៅឲ្យម៉ូយខ្លួនតែងតែទំនាក់ទំនងជាមួយឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា ហើយប្រាប់គាត់ថាធ្វើការងារឲ្យបានល្អកុំឲ្យបាត់បង់របស់គេ។ ចំពោះឈ្មោះ បាឡូ និងឈ្មោះ បាចា គឺជាឈ្មោះហៅក្រៅដែលជាអ្នកយកថ្នាំមកឲ្យឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា។ ឈ្មោះ [redacted] លាង ជាអ្នកទំនាក់ទំនង និងជាអ្នកយកលេខទូរស័ព្ទរបស់ឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា ឲ្យទៅឈ្មោះ បាឡូ ហៅ បាចា។ ឈ្មោះ [redacted] សៅ ជាអ្នកទំនាក់ទំនងយកលេខទូរស័ព្ទរបស់ឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា មកឲ្យខ្លួន។ ឈ្មោះ [redacted] ថាវី ខ្លួនអត់ស្គាល់ទេ តែឈ្មោះ [redacted] លាង ប្រាប់ខ្លួនថាឈ្មោះ [redacted] ថាវី ធ្លាប់បានទិញថ្នាំញៀនពីឈ្មោះ [redacted] លាង ម្តង០៥គីឡូក្រាម។ ឈ្មោះ [redacted] លាង ជាអ្នកបញ្ជាឲ្យឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា យកថ្នាំញៀនទៅទុកនៅបន្ទប់គាត់។ ឈ្មោះ [redacted] លាង គាត់ចេះនិយាយភាសាអង់គ្លេស និងជាអ្នកទំនាក់ទំនងការងារជាមួយជនបរទេស រាល់ពេលដែលឈ្មោះ [redacted] លាង ទំនាក់ទំនងជាមួយឈ្មោះ បាឡូ ជាភាសាអង់គ្លេសខ្លួនស្តាប់មិនបានទេ តែខ្លួនដឹងតាមរយៈកាយវិការរបស់ឈ្មោះ [redacted] លាង តែប៉ុណ្ណោះ។

៥-ជនជាប់ចោទឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា និងឈ្មោះ [redacted] វង្ហា ហៅ សឹង បានឆ្លើយសារភាពចំពោះអំពើរបស់ខ្លួន ដែលមានភាពស៊ីសង្វាក់នឹងភស្តុតាងដែលក្នុងសំណុំរឿង ដែលនាំឲ្យតុលាការមានភាពជឿជាក់បាន។

៦-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សៅ បានឆ្លើយថា ខ្លួនមិនបានជួញដូរគ្រឿងញៀនទេ ខ្លួនគ្រាន់តែដឹងថាឈ្មោះ [redacted] លាង និងពួកជនជាតិស្បែកខ្មៅគឺជាមេក្លោងជួញដូរគ្រឿងញៀន ចម្លើយនេះគ្រាន់តែជាការដោះសាររបស់ជនជាប់ចោទ មិនអាចឲ្យតុលាការជឿបាន ទេ ព្រោះតាមចម្លើយជនជាប់ចោទឈ្មោះ [redacted] វង្ហា បានបញ្ជាក់ថា ឈ្មោះ [redacted] សៅ បានទទួលការបញ្ជាពីឈ្មោះ យ៉ាំង លាង ឲ្យផ្ញើលេខទូរស័ព្ទទៅឲ្យឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា ដើម្បីលក់គ្រឿង ញៀន។

៧-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] SAMUEL ហៅ បាឡូ និង ឈ្មោះ [redacted] BENTO មានភាពស៊ីសង្វាក់គ្នាថា៖ ខ្លួនមិនមានទាក់ទងអ្វីជាមួយឈ្មោះ [redacted] លាង, ឈ្មោះ [redacted] វង្ហា និងឈ្មោះ [redacted] សៅ ឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា ឈ្មោះ [redacted] ថាវី នោះទេ ហើយក៏មិនដែលស្គាល់ពួកគេដែល ហើយចំពោះឈ្មោះ បាឡូ នោះគឺមិនមែនជាឈ្មោះរបស់ខ្លួនទេ ខ្លួនមិនដឹងថាហេតុអ្វីបានជាគេហៅឈ្មោះខ្លួនថា បាឡូ ទេ នេះគ្រាន់តែជាចម្លើយដោះសារដើម្បីឲ្យរួចខ្លួនពីការចោទប្រកាន់តែប៉ុណ្ណោះ ជនជាប់ចោទពុំមានភស្តុតាងផ្ទុយ ឬសាក្សីដោះ

103/6

បន្ទុកទេ តែបើតាមចម្លើយជនជាប់ចោទឈ្មោះ [redacted]វង្ហា ហៅ សឹង បានបញ្ជាក់ថា ឈ្មោះ បាឡា ដែលជាឈ្មោះហៅក្រៅរបស់ឈ្មោះ [redacted]SAMUEL ដែលជាអ្នកយកថ្នាំមកឲ្យឈ្មោះ[redacted] ធូរ៉ា ហៅ ត្រា។ ម្យ៉ាងទៀតឈ្មោះ [redacted]ធូរ៉ា ហៅ ត្រា ក៏បានបញ្ជាក់ផងដែលថាអ្នកដែលប្រគល់ថ្នាំញៀនមកឲ្យខ្លួននេះគឺជាជនជាតិស្បែកខ្មៅ។

៨-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] លាង បានឆ្លើយបដិសេធថា ខ្លួនមិនមានទំនាក់ទំនងអ្វីជាមួយជនបរទេសទាំងពីរនាក់នេះទេ ព្រោះខ្លួនអត់ចេះភាសាអង់គ្លេស។ ចំពោះទូរស័ព្ទក៏ខ្លួនអត់មានប្រើដែរ ហើយចំពោះទូរស័ព្ទដៃម៉ាកNចុចពិលនោះមិនដឹងជារបស់អ្នកណាទេ ចម្លើយនេះគ្រាន់តែជាការដោះសារដើម្បីឲ្យរួចខ្លួនពីការចោទប្រកាន់តែប៉ុណ្ណោះ ពុំអាចឲ្យតុលាការជឿបានឡើយ តែបើតាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា បានបញ្ជាក់ថា ឈ្មោះ[redacted] លាង គឺជាអ្នកបញ្ជា និងជាអ្នកទំនាក់ទំនងទៅម៉ូយឲ្យខ្លួនដឹកជញ្ជូនថ្នាំញៀនឲ្យគេ ម្យ៉ាងទៀតចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]ង្ហា ហៅ សឹង ក៏បានបញ្ជាក់ថាឈ្មោះ[redacted] លាង បានមកសុំលេខទូរស័ព្ទរបស់ឈ្មោះ[redacted]ធូរ៉ា ហៅ ត្រា ពីខ្លួនដើម្បីទំនាក់ទំនងទៅឈ្មោះ[redacted]ធូរ៉ា ហៅ ត្រា ឲ្យដឹកជញ្ជូនថ្នាំញៀនឲ្យគេ និងជាអ្នកទំនាក់ទំនងជាមួយជនបរទេសស្បែកខ្មៅដោយប្រើប្រាស់ភាសាអង់គ្លេសក្នុងការរកស៊ីជួញដូរថ្នាំញៀន។ មួយវិញទៀតតាមចម្លើយរបស់លោក[redacted] សុភាព ជាមន្ត្រីនគរបាលយុត្តិធម៌បានបញ្ជាក់ថា នៅពេលដែលចាប់ខ្លួនឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា សមត្ថកិច្ចបានឲ្យឈ្មោះ [redacted]រ៉ា ហៅ ត្រា ទូរស័ព្ទទំនាក់ទំនងទៅឈ្មោះ[redacted] សៅ, ឈ្មោះ[redacted] វង្ហា និងឈ្មោះ [redacted] លាង នៅក្នុងពន្ធនាគារព្រៃស ហើយសមត្ថកិច្ចក៏ចុះទៅពន្ធនាគារព្រៃស ហើយនាំជនជាប់ចោទទាំងបីនាក់មកសាកសួរ ទើបដឹងថាមានមេក្លោងថ្នាំញៀនចំនួន ០៣នាក់ទៀតជាជនបរទេស។

៩-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]ធូរ៉ា ហៅ ត្រា ឈ្មោះ[redacted] សៅ ឈ្មោះ[redacted] វង្ហា ឈ្មោះ [redacted] លាង ឈ្មោះ [redacted] SAMUEL ហៅ បាឡា និង ឈ្មោះ [redacted] BENTO និងការបំភ្លឺរបស់មន្ត្រីនគរបាលយុត្តិធម៌លោក [redacted]សុភាព និងកស្តុតាងដែលមានក្នុងសំណុំរឿង បញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] ធូរ៉ា ហៅ ត្រា ឈ្មោះ[redacted] សៅ ឈ្មោះ[redacted] វង្ហា ឈ្មោះ[redacted] លាង ឈ្មោះ [redacted]SAMUEL ហៅ បាឡា និង ឈ្មោះ[redacted] BENTO ពិតជាបានចូលរួមក្នុងការធ្វើសកម្មភាពទិញ លក់ គ្រឿងញៀនប្រភេទក្រាមម្សៅ និងប្រភេទគ្រាប់ ប្រាកដមែន ដែលអំពើរបស់ជនជាប់ចោទឆ្លើយតបនឹងធាតុផ្សំនៃបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងក្នុងមាត្រា ៤០ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១០-តាមកំណត់ហេតុធ្វើតេស្តពិសោធន៍បឋម និងវេចខ្ចប់វត្ថុតាងលេខ ០៥៣/១៦ ក.ប.គ.ញ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦ របស់ការិយាល័យបទល្មើសគ្រឿងញៀន បានបញ្ជាក់ថា គ្រឿងញៀនខុសច្បាប់មានសណ្ឋានជា ក្រាមពណ៌សថ្លាចំនួន ២១ កញ្ចប់ធំ ដែលមានទម្ងន់សុទ្ធសរុប ៣០១២,៩១ (បីពាន់សូន្យរយដប់ពីរក្បៀសប្រាំបួនក្រាម) បានដកហូតពីឈ្មោះ [redacted] ធូរ៉ា ហើយតាមលទ្ធផលកោសលវិច័យគ្រឿងញៀនបញ្ជាក់ថា គ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ មេតំហ្វេតាមីន (ហៅក្រៅអាយ ឬម៉ាទឹកកក ឬអាយ) ដែលមានកម្រិត ភាពសុទ្ធ ៨១,៩៩% នៃទម្ងន់សរុប



Scanned with CamScanner

នាំឲ្យជាតុសុទ្ធសរុបនៃគ្រឿងញៀនមេតំហ្វេតាមីនសរុបចំនួន ២៤៧០,២g (ពីរពាន់បួនរយចិតសិបក្បៀសពីក្រាម) និងថ្នាំគ្រាប់ពណ៌ផ្កាឈូកចំនួន ៥១៨កញ្ចប់ ដែលមានទម្ងន់ សុទ្ធសរុប ១០៤១០,៧g(មួយម៉ឺនសូន្យពាន់បួនរយដប់ក្បៀសប្រាំពីក្រាម) បានដកហូតពីឈ្មោះ [redacted] ធូរ៉ា ដែលហើយតាមលទ្ធផលកោសលវិច័យគ្រឿងញៀនបញ្ជាក់ថា គ្រឿងញៀនប្រភេទគ្រាប់ ឈ្មោះ មេតំហ្វេតាមីន (ហៅក្រៅ យ៉ាបា ឬថ្នាំឆ្កួត) ដែលមានកម្រិតភាពសុទ្ធ ១៦,៦០% នៃទម្ងន់ សរុប នាំឲ្យជាតុសុទ្ធសរុបនៃគ្រឿងញៀនមេតំហ្វេតាមីនសរុបចំនួន ១៧២៨.១g (មួយពាន់ប្រាំពីររយម្ភៃប្រាំបីក្បៀសមួយក្រាម) ដែលចំនួននេះតាមមាត្រា ៤០ កថាខណ្ឌទី៧ ចំណុចទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដែលចែងឲ្យផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ)ឆ្នាំ ទៅ ៣០ (សាមសិប)ឆ្នាំ ឬអស់មួយ ជីវិត និងផ្តន្ទាទោសពិន័យជាប្រាក់ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល ទៅ ១០០.០០០.០០០ (មួយរយលាន) រៀល។

១១-តាមសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការនាពេលសវនាការថា សុំរក្សាការចោទប្រកាន់ដដែល និងសុំឲ្យតុលាការពិនិត្យ សម្រេចតាមច្បាប់ គប្បីតុលាការពិចារណា។

១២-តាមពាក្យស្នើសុំចូលជាភ្នាក់ងារផ្តល់ព័ត៌មាន ប្រវត្តិរូបភ្នាក់ងារផ្តល់ព័ត៌មាន ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ២០១៦ របាយការណ៍ លទ្ធផល ការស្រាវជ្រាវ ស៊ើបអង្កេត នាយកដ្ឋានរិយាល័យប្រឆាំងការសំអាតប្រាក់លេខ ០២៦ រ.ប.ក ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ របស់ការិយាល័យប្រឆាំងការសំអាតប្រាក់ នៃមន្ទីរប្រឆាំងគ្រឿងញៀន លិខិតលេខ ៣៩៤ ល.ស ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៦ របស់មន្ទីរប្រឆាំងគ្រឿងញៀន និងលិខិតលេខ ០៥៧ ស.ជ.ណ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៧ បញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] ថារី ហៅ ឡុង [redacted] ហៅ រី ពិតជាកម្លាំងសម្ងាត់របស់មន្ទីរប្រឆាំងគ្រឿងញៀន ដែលមានលេខសម្គាល់ A5-32 ប្រាកដមែន ដូច្នេះ តុលាការគប្បីពិចារណា។

១៣-តាមចម្លើយជនជាប់ចោទឈ្មោ [redacted] ធូរ៉ា ហៅ ត្រា និងជនជាប់ចោទឈ្មោ [redacted] វង្សា បានបញ្ជាក់ថា ពួកគេមិនដែលស្គាល់ជនជាប់ចោទឈ្មោះ [redacted] ថារី ហៅ [redacted] ារី ហៅ រី ទេ ចំពោះជនជាប់ចោទដទៃទៀត ក៏មិនបានឆ្លើយពាក់ព័ន្ធនឹងជននេះដែរ ចំណែកភស្តុតាងដែលមានក្នុងសំណុំរឿងក៏មិនមានភស្តុតាងណាមួយដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ថារី ហៅ [redacted] ារី ហៅ រី ដូច្នេះ ដើម្បីជានាដល់ភាពយុត្តិធម៌ និងការខំប្រឹងប្រែងបំពេញការងារជាកម្លាំងសម្ងាត់ តុលាការគប្បីសម្រេចឲ្យជនជាប់ចោទឈ្មោះ [redacted] ថារី ហៅ [redacted] ារី ហៅ រី រួចខ្លួនពីបទចោទប្រកាន់ ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចចំណតរថយន្តក្រុងក្រុមហ៊ុនអង្គរអ៊ិចប្រេស ផ្លូវជាតិលេខ៥ ក្រុម១៤ ភូមិផ្សារតូច សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ និងបន្ទប់ជួលលេខ៧៧ ភូមិ៤ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៨, ២៩ ខែកុម្ភៈ និងថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងបញ្ជប់ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ២៥៩ ដចន ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

១៤-តាមសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ផូរ៉ា ហៅ ត្រា បានស្នើសុំក្រុមប្រឹក្សាមេត្តាផ្តន្ទាទោសកូនក្តីខ្លួនត្រឹមអប្បបរិមានៃទោសតែអំពើដែលជនជាប់ចោទប្រព្រឹត្តមានកម្រិតប៉ះពាល់ដល់សង្គមធ្ងន់ធ្ងរពេក ហេតុនេះតុលាការ គប្បីពិចារណាពីការសហការរបស់ជនជាប់ចោទ និងផលប៉ះពាល់ដែលកើតចេញពីអំពើរបស់ជនជាប់ចោទ។

១៥-តាមសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សៅ និងឈ្មោះ [redacted] ង្ហា បានស្នើសុំក្រុមប្រឹក្សាមេត្តាលើកលែងចោទប្រកាន់ដល់កូនក្តីខ្លួនឈ្មោ[redacted] វង្ហា និងសុំបន្ធូរបន្ថយទោសឈ្មោ[redacted] ង្ហា ចំពោះការសុំលើកលែងចោទប្រកាន់លើឈ្មោះ [redacted] សៅ គឺពុំត្រឹមត្រូវទេ ដោយហេតុថាមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទ បើទោះបីជនជាប់ចោទបានបដិសេធក៏ដោយតែជនជាប់ចោទមិនមានភស្តុតាងផ្ទុយណាមួយដែលអាចឲ្យតុលាការជឿជាក់បានថា ជនជាប់ចោទមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ចំណែកឯ ជនជាប់ចោទឈ្មោះ [redacted] វង្ហា បានសារភាពពីអំពើដែលខ្លួនបានប្រព្រឹត្តមែន តែអំពើរបស់ជនជាប់ចោទ បានជះឥទ្ធិពលអាក្រក់ដល់សង្គមខ្លាំងពេក ដែលតុលាការមិនគួពិចារណាពីការសម្រាលទោសលើជនជាប់ចោទឡើយ។

១៦-តាមសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] SAMUEL និងឈ្មោះ [redacted] BENTO បានស្នើសុំក្រុមប្រឹក្សាមេត្តាលើកលែងចោទប្រកាន់ដល់កូនក្តីខ្លួនទាំងពីរនាក់ឲ្យមានសេរីភាពវិញ ឃើញថា មិនមានភាពត្រឹមត្រូវទេ ដោយសារតាមចម្លើយជនជាប់ចោទឈ្មោះ [redacted] វង្ហា ហៅ ស៊ីង ឈ្មោះ [redacted] ផូរ៉ា ហៅ ត្រា តាមការបំភ្លឺរបស់មន្ត្រីនគរបាលយុត្តិធម៌ និងភស្តុតាងដែលក្នុងសំណុំរឿង បញ្ជាក់បានថា ជនជាប់ចោទទាំងពីរពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ដូច្នេះ តុលាការមិនពីការស្នើសុំរបស់មេធាវីការពារសិទ្ធិជនជាប់ចោទទេ។

១៧-តាមសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ថារី ហៅ [redacted] រ៉ារី បានស្នើសុំក្រុមប្រឹក្សាជំនុំជម្រះមេត្តាបញ្ឈប់ការចាប់ខ្លួនកូនក្តីខ្លួន និងសុំឲ្យកូនក្តីខ្លួនឈ្មោះ [redacted] ថារី ហៅ [redacted] រ៉ារី រួចផុតពីបទចោទប្រកាន់ ឃើញថា មានលក្ខណៈត្រឹមត្រូវដែលតុលាការគប្បីពិចារណា។

១៨-តាមសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] លាង បានស្នើសុំលើកលែងចោទប្រកាន់ដល់កូនក្តីខ្លួនឈ្មោះ [redacted] លាង គឺពុំត្រឹមត្រូវទេ ដោយហេតុថាមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទ។

១៩-តាមសំដីចុងក្រោយរបស់ជនជាប់ចោទនៅពេលសវនាការបានសុំឲ្យតុលាការបន្ធូរបន្ថយទោស និងសុំលើកលែងចោទប្រកាន់ តែអំពើរបស់ជនជាប់ចោទបានធ្វើឲ្យប៉ះពាល់ដល់សង្គមខ្មែរយ៉ាងធ្ងន់ធ្ងរ ដូច្នេះ តុលាការគប្បីពិចារណា។

២០-តាមចម្លើយរបស់ជនជាប់ចោទ ការបំភ្លឺរបស់មន្ត្រីនគរបាលយុត្តិធម៌ និងតាមភស្តុតាងដែលមានក្នុងសំណុំរឿង ឃើញថា ឈ្មោ[redacted] រ៉ា ហៅ ត្រា ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ,ឈ្មោះ [redacted] លាង ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិវៀតណាម, ឈ្មោះ [redacted] សៅ ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិខ្មែរ, ឈ្មោ[redacted] វង្ហា ហៅ ស៊ីង ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិខ្មែរ, ឈ្មោ[redacted] SAMUEL ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិ NIGERIAN និងឈ្មោះ [redacted] BENTO ភេទប្រុស



Scanned with CamScanner

អាយុ៤១ឆ្នាំ ជនជាតិ BISSAU កើតនៅប្រទេស GUINEA ពិតជាបានធ្វើសកម្មភាពទិញគ្រឿងញៀនយកទៅលក់បន្តដោយខុសច្បាប់ ដែលអំពើនេះឆ្លើយតបនឹងធាតុផ្សំនៃបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ហើយតាមលទ្ធផលកោសលវិច័យ បញ្ជាក់ថា គ្រឿងញៀនប្រភេទក្រាមម្សៅ និងគ្រឿងញៀនប្រភេទគ្រាប់ ដែលដកហូតពីជនជាប់ចោទ គឺមានឈ្មោះ មេតំហ្វេតាមីន ដែលតាមការគណនា ឃើញមានកម្រិតបរិមាណជាតុសុទ្ធសរុបនៃគ្រឿងញៀនមេតំហ្វេតាមីនសរុបចំនួន ១៧២៨.១g (មួយពាន់ប្រាំពីររយម្ភៃប្រាំបីក្បៀសមួយក្រាម) ដែលចំនួនបរិមាណជាតុសុទ្ធនេះឆ្លើយតបនឹងការផ្តន្ទាទោស តាមមាត្រា៤០ កថាខណ្ឌទី៧ ចំណុចទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២១-ជនជាប់ចោទ ជានីតិជនមានស្មារតី មានការយល់ដឹងគ្រប់គ្រាន់ក្នុងការពិចារណា និងបានដឹងយ៉ាងច្បាស់នូវអំពើរបស់ខ្លួនថាជាអំពើខុសច្បាប់ ដូច្នេះ ត្រូវតែទទួលខុសត្រូវលើអំពើរបស់ខ្លួនចំពោះមុខច្បាប់។

២២-អំពើរបស់ជនជាប់ចោទ បានធ្វើឲ្យប៉ះពាល់ដល់សុខភាព សន្តិសុខសង្គម និងសណ្តាប់ធ្នាប់សាធារណៈ និងបំពានដល់ច្បាប់រដ្ឋជាធរមាន។

២៣-មានកស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់ទៅលើជនជាប់ចោទឈ្មោះ [redacted] ផូរ៉ា ហៅ ត្រា ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] លាង ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិវៀតណាម, ឈ្មោះ [redacted] សៅ ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] វង្ហា ហៅ សឹង ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] SAMUEL ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិ NIGERIAN និងឈ្មោះ [redacted] BENTO ភេទប្រុស អាយុ៤១ឆ្នាំ ជនជាតិ BISSAU ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចចំណតរថយន្តក្រុងក្រុមហ៊ុនអង្គអ៊ិចប្រេស ផ្លូវជាតិ លេខ៥ ក្រុម១៤ ភូមិឫស្សីគូច សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ និងបន្ទប់ជួល លេខ៧៧ ភូមិ៤ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨ ថ្ងៃទី២៩ ខែកុម្ភៈ និងថ្ងៃទី០១ខែមីនា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៣ និងកថាខណ្ឌទី៧ ចំណុចទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២៤-តាមកំណត់ហេតុទទួលវត្ថុចាប់យកលេខ ៣៨៣ អ.យ.ធ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ ២០១៦ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញរួមមាន៖

ក.ស្រោមសំបុត្រពណ៌សបិទផ្លាស្ទិកជិតមានសរសេរថា ថ្នាំគ្រាប់ពណ៌ផ្កាឈូកមានទម្ងន់ថ្នាំសុទ្ធ ៣.០៤ ក្រាម ប្រកចូលក្នុងកូនថង់តូចៗចំនួន ៣។

ខ.ស្រោមសំបុត្រពណ៌សបិទផ្លាស្ទិកជិតមានសរសេរថា ក្រាមពណ៌សថ្លាមាន ទម្ងន់ជាក្រាមសុទ្ធ ៨.០២ ក្រាម ប្រកចូលក្នុងកូនថង់តូចៗចំនួន៣។

គ.ទូរស័ព្ទដៃពីរគ្រឿងម៉ាកណូគាអិនចុចពិលពណ៌ខ្មៅលាយខៀវមួយគ្រឿង និង ម៉ាកសាំសុងពណ៌សមួយគ្រឿង។

ឃ.ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនមួយគ្រឿង។



Scanned with CamScanner

ង.ថង់ពណ៌ស មានដាក់កូនសៀវភៅពណ៌ខ្មៅតូចចំនួន១,កាសទូរស័ព្ទអាយហ្វូនចំនួន១, ឡាមសម្រាប់កាត់មួយប្រអប់ និងកូនម៉ូឌឹមតូចពណ៌ខ្មៅចំនួន១ និងឯកសារផ្សេងៗ។

ច.ថង់ពណ៌ស មានកូនថង់តូចសម្រាប់ដាក់គ្រឿងញៀន។

ឆ.ប្រអប់ពណ៌ប្រផេះមានអក្សរដាក់ថា Pedro ចំនួន ១។

ជ.កេសដែកដាក់គ្រឿងញៀនពណ៌ផ្ទៃមេឃបិទជិត ដោយគណៈកម្មាការត្រួតពិនិត្យវត្ថុតាងចំនួន ១។

វត្ថុតាងខាងលើនេះមានជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទល្មើស គប្បីរឹបអូស ។

២៥-តាមដីកាសម្រេចលេខ ៤៨៥ "ច"ព្រទ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញបានសម្រេច រឹបអូសសារធាតុញៀនប្រភេទ មេតំហ្វេតាមីន (Methamphetamine) ហៅថា ក្រាមពណ៌សថ្លាចំនួន២១កញ្ចប់ធំ ដែលមានទម្ងន់សរុបចំនួន ៣០១២,៩g (បីពាន់សូន្យរយដប់ពីរក្បៀសប្រាំបួនក្រាម) និងថ្នាំគ្រាប់ពណ៌ផ្កាឈូកចំនួន ៥១៨ កញ្ចប់ ដែលមានទម្ងន់សុទ្ធសរុប ១០៤១០,៧g (មួយម៉ឺនសូន្យពាន់បួនរយដប់ក្បៀសប្រាំពីរក្រាម) ប្រគល់ឲ្យគណៈកម្មការបំផ្លាញគ្រឿងញៀនដើម្បីបំផ្លាញចោលរួចរាល់ហើយ។

## ហេតុដូច្នេះទើបសម្រេច

១-ផ្តន្ទាទោសជនជាប់ចោទ ៖

ក.ឈ្មោះ [redacted] ហៅ ត្រា ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិខ្មែរ

ខ.ឈ្មោះ [redacted] លាង ភេទប្រុស អាយុ ៣៧ឆ្នាំ ជនជាតិវៀតណាម

គ. ឈ្មោះ [redacted] សៅ ភេទប្រុស អាយុ ៤៥ឆ្នាំ ជនជាតិខ្មែរ

ឃ.ឈ្មោះ [redacted] វដ្ឋា ហៅ សឹង ភេទប្រុស អាយុ ៣៩ឆ្នាំ ជនជាតិខ្មែរ។

ង.ឈ្មោះ [redacted] SAMUEL ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិ NIGERIAN

ច.ឈ្មោះ [redacted] BENTO ភេទប្រុស អាយុ ៤១ឆ្នាំ ជនជាតិ BISSAU

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ អស់មួយជីវិត ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចចំណតរថយន្តក្រុងក្រុមហ៊ុនអង្គរអ៊ិចប្រេស ផ្លូវជាតិលេខ៥ ក្រុម១៤ ភូមិផ្សារតូច សង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ និងបន្ទប់ជួលលេខ៧៧ ភូមិ៤ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨, ២៩ ខែកុម្ភៈ និងថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៣ និងកថាខណ្ឌទី៧ ចំណុចទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-ឲ្យរួចខ្លួនពីបទចោទប្រកាន់លើ ឈ្មោះ [redacted] ថាវី ហៅ [redacted] វី ហៅ វី ភេទប្រុស កើតឆ្នាំ ១៩៨៣ ជាតិខ្មែរ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចចំណតរថយន្តក្រុងក្រុមហ៊ុនអង្គរអ៊ិចប្រេស ផ្លូវជាតិលេខ៥ ក្រុម១៤ ភូមិផ្សារតូច សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ និងបន្ទប់ជួលលេខ៧៧ ភូមិ៤ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៨, ២៩ ខែកុម្ភៈ និងថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned with CamScanner

៣-រឹបអូសវត្ថុចាប់យកដែលមានដូចក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ៣៨៣ អយជ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញរួមមាន៖

ក.ស្រោមសំបុត្រពណ៌សបិទផ្លាស្ទិកជិតមានសរសេរថា ថ្នាំគ្រាប់ពណ៌ផ្កាឈូកមានទម្ងន់ថ្នាំសុទ្ធ ៣.០៤ ក្រាម ប្រកចូលក្នុងកូនថង់តូចៗចំនួន ៣។

ខ.ស្រោមសំបុត្រពណ៌សបិទផ្លាស្ទិកជិតមានសរសេរថា ក្រាមពណ៌សថ្លាមានទម្ងន់ជាក្រាមសុទ្ធ ៨.០២ ក្រាម ប្រកចូលក្នុងកូនថង់តូចៗចំនួន៣។

គ.ទូរស័ព្ទដៃពីរគ្រឿងម៉ាកណូគាអិនចុចពិលពណ៌ខ្មៅលាយខៀវមួយគ្រឿង និងម៉ាកសាំសុងពណ៌សមួយគ្រឿង។

ឃ.ជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀនមួយគ្រឿង។

ង.ថង់ពណ៌ស មានដាក់កូនសៀវភៅពណ៌ខ្មៅតូចចំនួន០១, កាសទូរស័ព្ទអាយ ហ្វូនចំនួន០១, ឡាមសម្រាប់កាត់មួយប្រអប់ និងកូនម៉ូឌឹមតូចពណ៌ខ្មៅចំនួន០១ និងឯកសារ ផ្សេងៗ។

ច.ថង់ពណ៌ស មានកូនថង់តូចសម្រាប់ដាក់គ្រឿងញៀន។

ឆ.ប្រអប់ពណ៌ប្រផេះមានអក្សរដាក់ថា Pedro ចំនួន ១។

ជ.កេសដែកដាក់គ្រឿងញៀនពណ៌ផ្ទៃមេឃបិទជិត ដោយគណៈកម្មាការត្រួតពិនិត្យវត្ថុតាងចំនួន ១។

៤-បញ្ឈប់ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ២៥៩ ដចន ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៧ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ហៅ ត្រា, ឈ្មោះ [redacted] ហៅ សឹង, ឈ្មោះ [redacted] សៅ, ឈ្មោះ [redacted] SAMUEL, ឈ្មោះ [redacted] BENTO, ឈ្មោះ [redacted] លាង មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទលោក [redacted] ឡាយឃី, លោក [redacted] វណ្ណរ៉េត, លោក [redacted] ទីលីន, លោក [redacted] មុន្នីជាតិ, លោក [redacted] គ្រុយ លោកស្រី [redacted] សុខា កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ថាវី ហៅ [redacted] វី ហៅ វី និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៧។

ទុកសិទ្ធិឲ្យប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] | [redacted] | [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៧
ក្រឡាបញ្ជី

[redacted]

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

Scanned with CamScanner